00401539

D235/1

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 12 / NOV / 2009
ម៉ោង (Time/Heure) : 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. Fay

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: សហចៅក្រមស៊ើបអង្កេត

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ/

សម្ងាត់
CONFIDENTIAL
CONFIDENTIEL

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

13/11/2009

សាធារណៈ
PUBLIC
13/01/2010

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ពាក្យសុំរបស់លោក អៀង សារី ស្នើសុំចូលរួមជាមួយសំណើរបស់ នួន ជា សុំបង្កើតវិធានការនីតិវិធីជាក់លាក់**

---

**<u>ដាក់ដោយ</u>៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**<u>ផ្ញើជូន</u>៖**

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 14 / 01 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

តាមរយៈសហមេធាវីការពារក្តី លោក អៀង សារី បានស្នើសុំចូលរួមក្នុង "សំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់" របស់មេធាវីការពារក្តី នួន ជា ("សំណើសុំ")[1] ដែលស្នើសុំឱ្យក.ស.ច.ស៖

ក. ជូនដំណឹងដល់ភាគីទាំងអស់ឱ្យបានឆាប់បំផុត តាមតែអាចធ្វើបាន ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹងពីកាលបរិច្ឆេទពិតប្រាកដ ដែល កសចស មានផែនការដាក់ការជូនដំណឹង ក្រោមវិធាន ៦៦ ។

ខ. ដាក់បញ្ចូលលទ្ធផលថ្មី**ទាំងអស់**នៃការស៊ើបសួរទៅក្នុងសំណុំរឿង ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹងក្រោមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះគឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមរបស់មេធាវីការពារក្តីនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាព។

គ. សម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរដែលមិនទាន់សម្រេចទាំងអស់ ក្នុងរយៈពេលយ៉ាងយូរបំផុត**ពីរខែ** មុនពេលដាក់ការជូនដំណឹងក្រោមវិធាន ៦៦។ ក្របខណ្ឌពេលវេលានេះ គឺសំខាន់ចាំបាច់ ដើម្បីធានាដល់ការចូលរួមរបស់មេធាវីការពារក្តីនៅក្នុងនីតិវិធីប្រកបដោយប្រសិទ្ធិភាព ហើយនិង

ឃ. ឆ្លើយតបចំពោះសំណើនេះក្នុងរយៈពេលពីរ (២) សប្តាហ៍ បន្ទាប់ពីបានដាក់[2]។

ចំពោះការចូលរួមនឹងសំណើរនេះ មេធាវីការពារក្តីបានអនុម័តយកដោយគ្មានខដាក់លក្ខខណ្ឌនូវអង្គហេតុ និងទឡ្ហីករណ៍អង្គច្បាប់ទាំងអស់ដែលបានលើកឡើងដោយមេធាវីការពារក្តី នួន ជា។ ពាក្យសុំចូលរួមនេះមានសារៈសំខាន់ក្នុងការជៀសវាងនូវភាពអយុត្តិធម៌ជាក់ស្តែង ចំពោះជនត្រូវចោទទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២ ដូចបានរៀបរាប់នៅក្នុងសំណើសុំ ។ តាមរយៈការអនុម័តយកវិធានការទាំងនេះ មេធាវីការពារក្តីនឹងអាចដាក់បណ្តឹងឧទ្ធរណ៍ដ៏មានសារៈសំខាន់ ព្រាងសំណើសុំបំពេញកិច្ចស៊ើបសួរសំខាន់ៗបន្ថែម និង អាចរៀបចំសកម្មភាពរបស់ខ្លួនសម្រាប់ខែខាងមុខ ដែលប្រការនេះ វាអាចការពារនូវសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទនីមួយៗ។

---

[1] *រឿងក្តីរបស់ នួន ជា,* ០០២/១៩-០៩-២០០៧-អវតក/កសចស, សំណើសុំបង្កើតវិធានការនីតិវិធីជាក់លាក់ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០០៩។

[2] *ដូចខាងលើដែរត្រង់* កថាខណ្ឌ ៩។

00401541

ឯកសារ: D235/1



សូមលោកសហចៅក្រមទទួលយកសំណើសុំនេះដោយសេចក្ដីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្ដម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**